# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ១៧០/០៩ **គ.ជ.ប**

**ជម្រាបជូន**

**លោក លោកស្រីប្រធានគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** : អំពីការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការនៅតាមមណ្ឌលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ។

**យោង** : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឆ្នាំ២០០៩ ។

តាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបលោក លោកស្រីប្រធានគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប)ទាំងអស់ជ្រាប អំពីនីតិវិធីនៃការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការនៅតាមមណ្ឌលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ របស់គណបក្សនយោបាយទាំងនោះ ដូចខាងក្រោម៖

១- បន្ទាប់ពីបានទទួលស្គាល់ជាផ្លូវការលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយរួចហើយ និងក្រោយពីបានចាប់ឆ្នោតកំណត់លេខរៀងនៅលើសន្លឹកឆ្នោតហើយ គធ/ខប ត្រូវចាត់ចែងថតចម្លងបន្ថែមនូវបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមលំដាប់លេខរៀង និងតាមមណ្ឌលនីមួយៗ ដើម្បីបិទផ្សាយក្នុងមណ្ឌលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌពាក់ព័ន្ធតាមគោលដៅ ដូចខាងក្រោម ៖

- បិទផ្សាយនៅ គធ/ខប ចំនួន ០១ច្បាប់
- បិទផ្សាយនៅតាមសាលារាជធានី/ខេត្ត ចំនួន ០១ច្បាប់
- បិទផ្សាយនៅតាមសាលាក្រុង/ស្រុក/ខណ្ឌ ចំនួន ០១ច្បាប់ និង
- នៅតាមទីតាំងដែលនឹងអាចសន្មតថាជាទីតាំងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

២- គធ/ខប ត្រូវចាត់ចែងបិទផ្សាយក្នុងរយៈពេលយ៉ាងតិចសែសិបប្រាំ (៤៥)ថ្ងៃ មុនថ្ងៃបោះឆ្នោត គឺត្រូវរៀបចំបិទផ្សាយបន្ទាប់ពីបានចាប់ឆ្នោតកំណត់លេខរៀងនៅលើសន្លឹកឆ្នោតរួចហើយ ដោយមិនត្រូវឲ្យហួសថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ ឡើយ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធាន គធ/ខប ទាំងអស់យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ។

សូមលោក លោកស្រីប្រធាន គធ/ខប ទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩

**ត.ប. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

ទេព នីថា